**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការកំពូល
សំណុំរឿង រដ្ឋប្បវេណី
លេខៈ៤១២
ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០០
<u>សាលដីកា</u>
លេខៈ១០២
ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០១

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០១ ដោយមានសមាសភាពដូចតទៅៈ

១-ឯកឧត្តម **ឌិត មុន្នី** ជាប្រធាន
២-លោក **ស៊ិន ឌឹម** ជាចៅក្រម
៣-លោក **ប្រាក់ គឹមសាន** ជាចៅក្រម
៤-លោក **ជីវ កេង** ជាចៅក្រមជា
៥-លោក **សោម សិរីវឌ្ឍ** ជាចៅក្រម
៦-លោក **ប៉ែន ស៊ុន** ជាចៅក្រមរបាយការណ៍(អវត្តមាន)

<u>**ក្រឡាបញ្ជី**</u>

-លោកស្រី **យុត សគន្ធា**

<u>**តំណាងមហាអយ្យការ**</u>

-លោក **សាយ សារី** ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ៩៩(ច) ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ ២០០០ នៃសំណុំរឿងរដ្ឋប្បវេណីលេខ២៦០ ចុះថ្ងៃទី២៥-០៤-២០០០ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ អន ចេវ ភេទ ប្រុស អាយុ ៣៧ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីលំនៅភូមព្រែកខ្មែរ ឃុំស្អាងភ្នំ ស្រុកស្អាង ខេត្តកណ្តាល ។

ឈ្មោះអន ណាត ភេទស្រីអាយុ៤០ ឆ្នាំមុខរបរធ្វើស្រែទីលំនៅភូមិលេខ១ ឃុំត្រើយស្លា ស្រុកស្អាង ខេត្តកណ្តាល ។

ឈ្មោះអន វិត ភេទ ប្រុស អាយុ៣២ ឆ្នាំមុខរបរធ្វើស្រែ ទីលំនៅភូមិព្រែកសំរោង ឃុំកោះខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល ។

និងចុងចម្លើយបណ្តឹងសាទុក្ខឈ្មោះផុន ស្រ៊ី ភេទប្រុសជាតិខ្មែរ មុខរបរធ្វើស្រែ ទីលំនៅ ភូមិដំរីឆ្លង ឃុំស្អាងភ្នំ ស្រុកស្អាង ខេត្តកណ្តាល ។

<u>**កម្មវត្ថុបណ្តឹងៈ**</u> ប្តឹងទាមទារដីកេរ្តិ៍របស់ម្តាយ និងសុំបដិសេធកិច្ចសន្យាលក់ទិញ

តាមពាក្យបណ្តឹងសាទុក្ខលេខ៣៧៣ ចុះថ្ងៃទី១៣-០៩-២០០០ របស់លោកអន ចេវ ប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ ៩៩(ច) ចុះថ្ងៃទី១១-០៩-២០០០ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ៤១២ ចុះថ្ងៃទី១៦-១០-២០០០ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី១៥-០៧-៩៩ របស់ឈ្មោះអន ចេវ ប្តឹងពីឈ្មោះផុន ស្រ៊ី សុំសិទ្ធិគ្រប់គ្រងដី និងសុំបដិសេធកិច្ចសន្យាលក់-ទិញ ចុះថ្ងៃទី ២៣-០៧-៩៣ ដោយហេតុថាដីលំនៅដ្ឋាន នេះជាកម្មសិទ្ធិរបស់ម្តាយខ្លួនឈ្មោះតាំង សុខ ដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាន់លេខដេ៧-១២៤២ ចុះថ្ងៃទី៧-០៤-៩៣ នៅឆ្នាំ១៩៩៨ ម្តាយខ្លួននិងខ្លួនបានឯកភាពជួលដីនេះទៅឲ្យឈ្មោះផុន ស្រ៊ីធ្វើរោងម៉ាស៊ីនកិនស្រូវ។ នៅឆ្នាំ១៩៩៣ ម្តាយខ្លួនបានស្លាប់ប្អូនស្រីខ្លួនឈ្មោះអន មុំ ហ៊ានយកដីនេះទៅលក់ឲ្យឈ្មោះផុន ស្រ៊ីចំនួន៧ជីមាស ប្អូនស្រីខ្លួនទទួលបានមាសត្រឹមតែ ៤ជី កន្លះប៉ុណ្ណោះ នៅសល់២ជី៥ ហ៊ុនទៀត មិនទាន់ឲ្យរហូតដល់សព្វថ្ងៃ ។

បានឃើញសាលក្រមលេខ៥២(ក) ចុះថ្ងៃទី១៤-១២-៩៩ របស់តុលាការខេត្តកណ្តាល ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅៈ

១-ទទួលស្គាល់ថា ដីដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់លេខដេ៧-១២៤២ មានទីតាំងស្ថិតនៅភូមិព្រែកខ្មែរ ឃុំស្អាងភ្នំ ស្រុកស្អាង ខេត្តកណ្តាល ជាបេតិកភ័ណ្ឌរបស់សពលោកយាយតាំង សុខ ដែលត្រូវបន្តឲ្យទៅទាយាទឈ្មោះអន ណាត, ឈ្មោះអន ចេវ, ឈ្មោះអន វិត និង ឈ្មោះអន មុំ ។

២-ចាត់ទុកជាមោឃៈនូវកិច្ចសន្យា ចុះថ្ងៃទី២៣-០៧-៩៣ រវាងឈ្មោះអន មុំ និងឈ្មោះផុន ស្រ៊ី ។

៣-បង្គាប់ឲ្យឈ្មោះផុន ស្រ៊ី បញ្ឈប់នូវសកម្មភាពប្រើប្រាស់លើដីដែលបានសម្រេចត្រង់ចំណុចទី១

៤-បង្គាប់ឲ្យនាង អន មុំ សងមាសចំនួន ៤ជី ៥ហ៊ុន មាសទឹក៩៧ និងការប្រាក់៥% ក្នុងមួយឆ្នាំ គិតពី ថ្ងៃទី២៣-០៧-៩៣ រហូតដល់ថ្ងៃទូទាត់រួចទៅឲ្យឈ្មោះផុន ស្រ៊ី នាពេលសាលក្រមស្ថាពរ ។ករណីរឹងទទឹងត្រូវអនុវត្តតាមច្បាប់ ស្តីពីការអនុវត្តសាលក្រមរដ្ឋប្បវេណី ។

៥-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ៧០០០៛ ដែលដើមចោទបានបង់រួច ហើយឲ្យចុងចម្លើយសងទៅដើមចោទវិញ ។

៦-បង្គាប់ឲ្យនាង អន មុំ បង់ពន្ធសមាមាត្រតាមអត្រា១% លើប្រាក់សំណង និងការប្រាក់ដែលឈ្មោះនេះត្រូវសងទៅឲ្យឈ្មោះផុន ស្រ៊ី ។

៧-សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវប្តឹងឧទ្ធរណ៍រយៈពេល២ខែ គិតពីថ្ងៃនេះតទៅ ។

មិនសុខចិត្តនិងសាលក្រមនេះឈ្មោះផុន ស្រ៊ី បានប្តឹងឧទ្ធរណ៍តាមបណ្តឹងលេខ០៥ ចុះថ្ងៃទី១៧-០១-២០០០ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៩៩(ច) ចុះថ្ងៃទី១១-០៩-២០០០ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅៈ

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៧-០១-២០០០ របស់ឈ្មោះផុន ស្រ៊ី ទុកជាត្រឹមត្រូវតាម ទម្រង់ និង គតិច្បាប់ ។

២-បដិសេធសាលក្រមរដ្ឋប្បវេណីលេខ ៥២ (ភ) ចុះថ្ងៃទី១៤-១២-៩៩ របស់តុលាការខេត្ត កណ្តាល ចោលជាអសារបង់ ។

៣-ប្រគល់ដីទំនាស់ស្ថិតនៅភូមិព្រែកខ្មែរ ឃុំស្អាងភ្នំ ស្រុកស្អាង ខេត្តកណ្តាល ដែលមានប័ណ្ណ សម្គាល់សិទ្ធិកាន់កាប់ដីធ្លីលេខដេ៧-១២៤២ ចុះថ្ងៃទី២៨-០៩-៩២ ឲ្យទៅឈ្មោះផុន ស្រ៊ី កាន់កាប់ជាកម្ម សិទ្ធិតទៅ ។

៤-ឲ្យឈ្មោះផុន ស្រ៊ី សងប្រាក់ថ្លៃទិញដីចំនួនពីរជី៥ហ៊ុន ២,៥លី បន្ថែមទៀតឲ្យទៅឈ្មោះអន មុំ ចាប់ពីពេលដែលដីការនេះចូលជាស្ថាពរ ។

៥-ទុកសិទ្ធិឲ្យឈ្មោះអន ណាត,អន ចេវ ,និងអន វិត ប្តឹងទាមទារចំណែកមរតកពីឈ្មោះអន មុំ វិញ ។

៦-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០៛ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង ២.៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់ ៤៥០៛ ចំណាយក្នុងកិច្ចប្រគល់ដីកាកោះ ៥.០០០៛ និងលើ អាជ្ញាធរតុលាការ៥.០០០៛សរុបចំនួន ១៣.០០០៛ និងបង្គាប់ឲ្យដើមចោទបង់ពន្ធសមាមាត្រ១%លើថ្លៃដី ទំនាស់។

៧-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខរបស់ឈ្មោះ ផុន ស្រ៊ី ស្ថិតក្នុងកំណត់ច្បាប់ ។

បានឃើញសារណារបស់ឈ្មោះ អន ចេវ ចុះថ្ងៃទី ១៨-១០-២០០០ ។

បានឃើញសារណារបស់ឈ្មោះ ផុន ស្រ៊ី ចុះថ្ងៃទី ៦-១២-២០០០ ។

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថាៈ សូមក្រុមប្រឹក្សាជំនុំជំរះសម្រេចតាម ច្បាប់ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ អន ចេវ ដែលបានឆ្លើយនាពេលសវនាការថា ៖ ពេលម្តាយខ្លួននៅ រស់គាត់ជួលឲ្យគេធ្វើរោងម៉ាស៊ីនកិនស្រូវរហូតដល់ឆ្នាំ ១៩៩២ ។ ប័ណ្ណកម្មសិទ្ធិម្តាយខ្លួនធ្វើនៅឆ្នាំ ៩២ ។

ឆ្នាំ៩៩ ខ្លួនដាំដើមចេក ស្រាប់ឈ្មោះផុន ស្រ៊ី យកកម្លាំងមកកាប់ចោលហើយនិយាយ ថាដីនេះគាត់ទិញពីប្អូនខ្លួន ទើបខ្លួនដឹងថាដីនេះប្អូនខ្លួនលួចលក់ ។

បានស្តាប់ចម្លើយរបស់ឈ្មោះអន ណាត ដែលបានឆ្លើយនាពេលសវនាការថា៖ខ្លួនសុំប្តឹងបដិសេធអ្នកលក់ និង អ្នកទិញ ។

បានស្តាប់ចម្លើយរបស់ឈ្មោះអន វិត ដែលបានឆ្លើយនាពេលសវនាការថា៖ខ្លួនក៏ដូចបងខ្លួនដែរ។

បានស្តាប់ចម្លើយឈ្មោះផុន ស្រ៊ី ដែលឆ្លើយនៅពេលសវនាការថា៖ពេលនៅរស់យាយតាំង សុខធ្លាប់គិតជាមួយខ្លួន និងអន មុំ ថាចង់លក់ដីតែពេលលក់ពិតប្រាកដ យាយសុខស្លាប់ហើយ ។

ការនិយាយថ្លៃគឺបាននិយាយជាមួយអន ណាត ទៀតផង ។

ដីនេះខ្លួនកាន់កាប់តាំងពីធ្វើកិច្ចសន្យារហូតមកដល់បច្ចុប្បន្ន ។

លោកប៉ិច វិច្ឆកា មេធាវីដើមចោទសន្និដ្ឋានថា៖ដីដែលអន មុំ លក់ជាដីសហកម្មសិទ្ធិ ។ឈ្មោះអន មុំ លក់ដោយគ្មានការយល់ព្រមពីបងប្អូន ហើយនៅជាអនីតិជន (អាយុប្រហែល១០ឆ្នាំ)

កិច្ចសន្យានេះមានតែស្នាមមេដៃ អ្នកលក់ និង អ្នកទិញប៉ុណ្ណោះគ្មានការបញ្ជាក់ពីរដ្ឋអំណាចទេ ។

-កិច្ចសន្យានេះជាកិច្ចសន្យាអវិភាគ

-អ្នកលក់ជាអនីតិជន

-គ្មានការយល់ព្រមពីអាណាព្យាបាលស្របច្បាប់ ហើយ អន មុំ ក៏បានសារភាពថាមិនបានប្រាប់បងដែរ ។

-កិច្ចសន្យានេះមិនទាន់ផុតអាជ្ញាយុកាលទេ ព្រោះកិច្ចសន្យាមិនទាន់បានបញ្ចប់ ដោយការប្រគល់លុយមិនទាន់គ្រប់ ។

ខ្លួនសុំតុលាការ មេត្តាបដិសេធសាលដីកាសាលាឧទ្ធរណ៍ ។

-ក្រោយពីស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់គូភាគី និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីដើមចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាឬទុក្ខលេខ៣៧៣ ចុះថ្ងៃទី១៣-០៩-២០០០ របស់លោកអន ចេវ ស្ថិតក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សម្រេចប្រគល់ដីទំនាស់នេះ ឲ្យទៅចុងចម្លើយដោយសំ

អាងលើ កិច្ចសន្យាលក់-ទិញ ចុះថ្ងៃទី២៣-០៧-៩៣ ហើយថាដើមចោទបានដឹងពីការលក់-ទិញ នេះ ហើយដោយពុំប្តឹងតវ៉ា ធ្វើឲ្យដើមចោទផុតអាជ្ញាយុកាលពុំអាចប្តឹងបានទៀត នោះជាការពុំត្រឹមត្រូវទេ ពីព្រោះដីទំនាស់នេះជាដីដែលមានប័ណ្ណកម្មសិទ្ធិជាទ្រព្យអវិភាគហើយការលក់-ទិញនេះ ពុំទាន់បានអនុវត្ត ជាស្ថាពរនៅឡើយ ដែលញ៉ាំងឲ្យដើមចោទនាមជាតតីយជនមានសិទ្ធិប្តឹងតវ៉ាបានតាមមាត្រា១៧៩-១៨០ និង១៨២ នៃច្បាប់ភូមិបាលនិងមាត្រា៤០ និង៤១ នៃក្រឹត្យ-ច្បាប់លេខ៣៨ក្រច ចុះថ្ងៃទី ២៨-១០-៨៨ ។

-យល់ឃើញថា ការលក់-ទិញ ដីទំនាស់រវាងចុងចម្លើយ និងឈ្មោះអន មុំ នៅថ្ងៃទី២៣-០៧-៩៣ ពុំមានភស្តុតាងណាថាឈ្មោះអន ចេវ -អន ណាត និងឈ្មោះអន រិត បានយល់ព្រមទេ ហើយនៅពេល លក់ដីទំនាស់នេះថ្ងៃទី ២៣-០៧-៩៣ ឈ្មោះអន មុំ ទើបតែមានអាយុ១៧ ឆ្នាំទេ ដែលតាមមាត្រា១៥ ក្រឹត្យច្បាប់លេខ៣៨ ក្រច ចុះថ្ងៃទី២៨-១០-៨៨ មិនអាចយកជាការបានឡើយ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៩៩(ច) ចុះថ្ងៃទី១១-០៩-២០០០ របស់សាលាឧទ្ធរណ៍ដែលសម្រេចសេចក្តីមកនេះ មានការខុសឆ្គងទាំងទម្រង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីចំពោះមុខគូក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ៣៧៣ ចុះថ្ងៃទី១៣ -០៩-២០០០ របស់លោកអន ចេវ ទុកជាត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ៩៩(ច) ចុះថ្ងៃទី១១-០៩-២០០០ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ៤១២ ចុះថ្ងៃទី១៦-១០-២០០០ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីដែលលោកអន ចេវ បានបង់ទុកនៅតុលាការកំពូលចំនួន១៩.០០០៛ គឺៈ

-ពន្ធចុះបញ្ជីក្តី និង ពន្ធហ្នឹងចំនួន ៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០៛ សរុប ១៩.០០០៛ ហើយតម្រូវឲ្យលោកផុន ស្រ៊ី សងប្រាក់ចំនួន ១៩.០០០៛ នេះទៅលោកអន ចេវ វិញ ។

៥-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៩-ខែកក្កដា ឆ្នាំ២០០០១ ។